**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

លេខ : ៣៥/១៧ .........ប.ស.ស

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## នីតិវិធីនៃការរាយការណ៍កម្មករនិយោជិតជាស្ត្រីដែលមានគភ៌ដើម្បីទាមទារប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាជូនកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន សម្រាប់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធដែលបានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម( ប.ស.ស )

**យោង** :
- អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- ប្រកាសអន្តរក្រសួងលេខ៨០៤ ក.ប/ប្រក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

បេឡាជាតិរបបសន្តិសុខសង្គម មានកិត្តិយសសូមជម្រាបជូនដល់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារអោយបានជ្រាបថា៖ ដើម្បីទទួលបាននូវប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវមានកាតព្វកិច្ចជូនដំណឹងមក ប.ស.ស អំពីភាពមានគភ៌ក្នុងរយៈពេលយ៉ាងយូរបីខែមុនកាលបរិច្ឆេទនៃការសម្រាលកូនតាមទម្រង់បង់ភាគទាន(E-form)ដែលប.ស.សបានកំណត់។ ក្នុងករណីខកខានមិនបានជូនដំណឹងតាមពេលកំណត់នេះសាមីខ្លួន ឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់ក្រោយពេលសម្រាលកូនយ៉ាងយូរបំផុតមួយខែមកប.ស.ស បើពុំនោះសោតនឹងបាត់បង់សិទ្ធក្នុងការទទួលបានប្រាក់ឧបត្ថម្ភបន្ថែមនេះ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងករណីខកខានមិនបានជូនដំណឹងអំពីភាពមានគភ៌របស់កម្មករនិយោជិតមកប.ស.ស ដែលនាំអោយបាត់បង់ប្រាក់ឧបត្ថម្ភបន្ថែមនេះ។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា លោក/លោកស្រី ជានិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតនឹងចូលរួមអនុវត្តតាមខ្លឹមសារនេះជាក់ជាពុំខាន។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ិត សមហៀង**

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ . ០២៣ ៨៨ ១០ ១៥ 
០២៣-៨៨ ១០ ១៦ . ០២៣ ៨៨ ០៤ ១៧
ទូរសារ : ០២៣ ៨៨ ២៦ ២៣ . ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh